# ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន (Environmental Justice Council)
## កិច្ចប្រជុំលើកទី #2
## ថ្ងៃព្រហស្បតិ៍ ទី15 ខែកញ្ញា ឆ្នាំ2022
## ម៉ោង10:30 ព្រឹក ដល់ម៉ោង12:30 រសៀល
## <u>កំណត់ហេតុកិច្ចប្រជុំ</u>

ទីកន្លែងប្រជុំ៖ កិច្ចប្រជុំតាមប្រព័ន្ធ Zoom

ឯកសារកិច្ចប្រជុំ៖ [របៀបវារៈ ផ្ទាំងស្លាយបទបង្ហាញ]

### សមាជិកក្រុមប្រឹក្សាដែលមានវត្តមាន៖

- Peter Maathey
- Marcos Luna
- Ari Zorn
- Caroline Hon
- Melissa Ferretti
- Kalila Barnett
- Patricia "Pat" Spence
- Cheryll Holley
- Namrita Kapur
- Lydia Lowe
- Madeline Fraser Cook

*ពុំមានសមាជិកក្រុមប្រឹក្សាណាម្នាក់ អវត្តមានពីកិច្ចប្រជុំ។ Madeline Fraser Cook បានចាកចេញពីកិច្ចប្រជុំមុនពេលកំណត់ នៅម៉ោង 11:33 ដើម្បីបំពេញកិច្ចការផ្សេងទៀត។*

### បុគ្គលិករបស់ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EOFEA) ដែលមានវត្តមាន៖

- Rishi Reddi នាយកផ្នែកយុត្តិធម៌បរិស្ថាន
- Vallery Cardoso នាយករងផ្នែកយុត្តិធម៌បរិស្ថាន
- Gary Moran ជាអនុលេខាធិការ ផ្នែកគោលនយោបាយបរិស្ថាននិងភាពធន់ទ្រាំនឹងអាកាសធាតុ
- Caroline Higley លេខាធិការជំនួយសម្រាប់គំនិតផ្តួចផ្តើមបរិស្ថាននិងយុទ្ធសាស្ត្រ និងការសម្របសម្រួលទីភ្នាក់ងារ

---

### របៀបវារៈ៖

1. មតិស្វាគមន៍ ការណែនាំ និងទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ
2. ការអនុម័តកំណត់ហេតុកិច្ចប្រជុំពីមុន
3. ការប្រកាស
   a. កិច្ចប្រជុំបែបចម្រុះ (ពីចម្ងាយ / ដោយផ្ទាល់) ដែលនឹងត្រូវរៀបចំនាពេលអនាគត
   b. ផែនទី EJ ដែលនឹងត្រូវធ្វើបច្ចុប្បន្នភាព និងកែសម្រួលឡើងវិញនៅត្រឹមថ្ងៃទី1 ខែតុលា
4. បទបង្ហាញដោយក្រុមជំនួបតុមូលនៃចលនាយុត្តិធម៌បរិស្ថាន
5. ការវិភាគលើនិយមន័យនៃ "ប្រជាជនអ្នកចូលរួម EJ"
   a. EJ ក្នុងបរិបទប្រវត្តិសាស្ត្ររបស់រដ្ឋម៉ាសាជូសេត៖ Marcos Luna
   b. កិច្ចពិភាក្សាអំពីផលិតផលការងាររបស់ក្រុមប្រឹក្សា EJC
   c. កិច្ចដំណើរការ / ប្រតិបត្តិការរបស់ក្រុមប្រឹក្សា EJC
6. បទបង្ហាញស្តីពីផែនការថាមពលស្អាតនិងអាកាសធាតុ
7. សំណួរ/មតិយោបល់ពីសាធារណជន
8. ជំហានបន្ទាប់ និងការលើកវារកាល

---

កិច្ចប្រជុំបានចាប់ផ្តើមនៅម៉ោង 10:31 នាទីព្រឹក។

## មតិស្វាគមន៍ ការណែនាំ និងទិដ្ឋភាពទូទៅនៃកិច្ចដំណើរការប្រជុំ៖

Rishi Reddi បានស្នើសុំសមាជិកក្រុមប្រឹក្សា EJC ធ្វើការណែនាំអំពីខ្លួនពួកគេ។ សមាជិកក្រុមប្រឹក្សាថ្មីពីររូប Cheryll Holley និង Kalila Barnett ត្រូវបានណែនាំខ្លួននៅក្នុងកិច្ចប្រជុំនេះ។

## ការអនុម័តកំណត់ហេតុកិច្ចប្រជុំមុន៖

Rishi ស្នើសុំធ្វើការអនុម័តកំណត់ហេតុកិច្ចប្រជុំថ្ងៃទី28 ខែកក្កដា ឆ្នាំ2022។ Patricia Spence ស្នើសុំធ្វើការអនុម័តកំណត់ហេតុប្រចាំខែកក្កដា។ Lydia Lowe គាំទ្រសំណើនោះ ហើយ Rishi ស្នើសុំធ្វើការបោះឆ្នោតដោយហៅឈ្មោះ។ Cheryll Holley និង Kalila Bennet មិនបានចូលរួមបោះឆ្នោតទេ ពីព្រោះពួកគេមិនមានវត្តមាននៅក្នុងកិច្ចប្រជុំដំបូងនោះឡើយ។ សមាជិកដទៃទៀតនៃក្រុមប្រឹក្សា EJ បានបោះឆ្នោតយល់ព្រមដើម្បីអនុម័តកំណត់ហេតុនៃកិច្ចប្រជុំ។

## ការប្រកាស៖

Rishi បានផ្តល់ព័ត៍មានថ្មីៗជូនដល់ក្រុមប្រឹក្សា EJC និងសាធារណជន។ ការប្រកាសទាំងនេះ រួមមាន៖

c. ការវិវត្តរីកចម្រើនឆ្ពោះទៅរកការរៀបចំកិច្ចប្រជុំក្រុមប្រឹក្សា EJC តាមបែបចម្រុះ (ពីចម្ងាយ/ដោយផ្ទាល់)។ ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA) កំពុងដំណើរការជ្រើសរើសអ្នកផ្តល់ប្រឹក្សាយោបល់ដើម្បីចាត់ចែងរៀបចំកិច្ចដំណើរការប្រជុំតាមបែបចម្រុះ។ មានសេចក្តីសង្ឃឹមទុកថា កិច្ចប្រជុំបែបចម្រុះនឹងប្រព្រឹត្តទៅនាពេលអនាគតដ៏ខ្លីខាងមុខនេះ។

d. ផែនទី EJ ដែលត្រូវធ្វើបច្ចុប្បន្នភាព និងកែសម្រួលឡើងវិញនៅត្រឹមថ្ងៃទី1 ខែតុលា ផែនទីដែលត្រូវធ្វើបច្ចុប្បន្នភាព នឹងដាក់បញ្ចូលទៅក្នុងទិន្នន័យជំរឿន។

Lydia Lowe បានស្នើសុំការបញ្ជាក់អំពីទិន្នន័យជំរឿន និងមណ្ឌលស្នាក់នៅរួម។ ទីក្រុងបូស្តុន បានស្នើសុំជំរឿននៃមណ្ឌលស្នាក់នៅរួម ហើយ Lydia មិនដឹងច្បាស់ថាតើទីក្រុងដទៃផ្សេងទៀតនៅក្នុងរដ្ឋនេះបានធ្វើជំរឿនបែបនោះដែរឬទេ។

តើប្រព័ន្ធព័ត៌មានភូមិសាស្ត្ររបស់ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA GIS) នឹងដាក់បញ្ចូលមណ្ឌលស្នាក់នៅរួមចូលទៅក្នុងទិន្នន័យថ្មីដែរឬទេ? Rishi បានឆ្លើយតបថា ការិយាល័យប្រតិបត្តិនៃកិច្ចការថាមពល និងបរិស្ថាន កំពុងធ្វើការដោះស្រាយបញ្ហានេះនាពេលឥឡូវនេះ ហើយនឹងសាកសួរអ្នកសម្របសម្រួលប្រព័ន្ធព័ត៌មានភូមិសាស្ត្ររបស់យើងអំពីវិធីសាស្ត្រដែលយើងដោះស្រាយជាមួយមណ្ឌលស្នាក់នៅរួម និងសាកសួរជាពិសេសអំពីទីក្រុងបូស្តុន។

## បទបង្ហាញដោយក្រុមចម្រុះយុត្តិធម៌បរិស្ថាន៖

Rishi បានស្នើសុំ Maria Belen Power នាយករងនៃ GreenRoots ធ្វើបទបង្ហាញរបស់ក្រុមចម្រុះ EJ។ Maria Belen បានណែនាំអំពីក្រុមចម្រុះ EJ និងកិច្ចការងារថ្មីចុងក្រោយបំផុតរបស់ក្រុមចម្រុះនេះ។

ចំណែកនៃបទបង្ហាញរបស់ Maria Belen ត្រូវបានសង្ខេបនៅទីនេះ៖

> ក្រុមចម្រុះ EJ ត្រូវបានបង្កើតឡើងនៅឆ្នាំ2018 ប៉ុន្តែក្រុមចម្រុះនេះ កសាងឡើងដោយផ្អែកលើកិច្ចការងារដែលត្រូវបានបំពេញជាច្រើនទសវត្សរ៍ដោយសម្ព័ន្ធមិត្តនិងដៃគូរបស់ EJ នៅទូទាំងរដ្ឋម៉ាសាជូសិត។ ក្រុមនេះបានជួបពិភាក្សាជាមួយគ្នាដើម្បីស្វែងរកវិធីសាស្ត្រសហការជាមួយគ្នាដើម្បីកំណត់និយមន័យនៃ EJ នៅក្រោយ ពេលពួកគេដឹងថា EJ ត្រូវបានលើកឡើងនៅក្នុងច្បាប់ប្រហែល 20 ផ្សេងៗគ្នា។
>
> Maria Belen ណែនាំឲ្យស្គាល់សមាជិករបស់ក្រុមចម្រុះ EJ។ សហប្រធានដឹកនាំការប្រជុំ គឺអង្គការ Alternatives for Community and Environment (ACE) អង្គការ GreenRoots អង្គការ Neighbor to Neighbor អង្គការ the Coalition for Social Justice និងអង្គការ North American Indian Center of Boston (NAICOB) ហើយនាពេលបច្ចុប្បន្នអង្គការទាំងនេះកំពុងពិភាក្សាជាមួយ អង្គការ Groundworks Lawrence ដើម្បីប្រែក្លាយអង្គការនេះទៅជាសហប្រធានដឹកនាំកិច្ចប្រជុំផងដែរ។ ប្រធានដឹកនាំកិច្ចប្រជុំតំណាងឲ្យសហគមន៍នៅទូទាំងរដ្ឋម៉ាសាជូសិតទាំងមូល។

សម្ព័ន្ធមិត្តនិងដៃគូដែលជាផ្នែកមួយរបស់ក្រុមចម្រុះ EJ គឺ៖ អង្គការ Green Energy Consumers Alliance អង្គការ Environmental League of Massachusetts (ELM) អង្គការ Clean Water Action អង្គការ Conservation Law Foundation (CLF) អង្គការ Lawyers for Civil Rights, Union of Concerned Scientists អង្គការ UU Mass Action និងអង្គការ Massachusetts Communities Action Network (MCAN)។ បន្ទាប់មក **Maria Belen** បានស្នើសុំ Sofia Owen ឲ្យបង្ហាញចំណែកបន្ទាប់នៃបទបង្ហាញ។

Sofia Owen ដែលជាមេធាវីតំណាងឲ្យបុគ្គលិកនិងជានាយកកម្មវិធីសេវាច្បាប់របស់ក្រុមចម្រុះបរិស្ថាននៅអង្គការ ACE បានបង្ហាញទិដ្ឋភាពទូទៅនៃប្រវត្តិនៃការវិវត្តរីកចម្រើនរបស់ EJ នៅក្នុងរដ្ឋម៉ាសាជូសិត ដោយចាប់ផ្តើមនៅ ឆ្នាំ1994 ដោយមានអង្គការបណ្តាញជំនួយគាំទ្រ EJ រដ្ឋម៉ាសាជូសិត (EJ Assistance Network) ដែលត្រូវគាំទ្រដោយអង្គការ ACE។ មតិយោបល់របស់ Sofia ត្រូវបានសង្ខេបនៅទីនេះ៖

អង្គការបណ្តាញជំនួយគាំទ្រ EJ MA បានប្រមូលផ្តុំសហគមន៍ មេធាវី អ្នកជំនាញឯកទេសទីតាំងដែលមានអាជ្ញាប័ណ្ណ អ្នកជំនាញវារិអគ្គិសនី អ្នកជំនាញវិជ្ជាជីវៈសុខាភិបាលសាធារណៈ និងអ្នកជំនាញផ្សេងទៀត។ ក្រុមនេះ បានដឹកនាំអង្គការ ACE ដើម្បីជំរុញឲ្យរដ្ឋបង្កើតក្រុមប្រឹក្សាផ្តល់យោបល់ EJ ដើម្បីជួយអភិវឌ្ឍ គោលនយោបាយ EJ ឆ្នាំ2002។

- **2002**៖ ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន ត្រូវបានបង្កើតឡើងដើម្បីជួយបង្កើតគោលនយោបាយ EJ របស់រដ្ឋ។
- **2009**៖ អង្គការ ACE បានបង្កើតអង្គការសម្ព័ន្ធ MA EJ Alliance ដែលនាំទៅដល់ការចេញបទបញ្ជានិតិប្រតិបត្តិរដ្ឋម៉ាសាជូសិត លេខ552 (MA Executive Order (EO) 552)។
- **2009-2010**៖ អង្គការ ACE បានបង្កើតអង្គការសម្ព័ន្ធ EJ Alliance ដែលជាក្រុមមួយដែលមានសមាជិកជាអង្គការថ្នាក់មូលដ្ឋានចំនួន 20 មកពីគ្រប់ទីកន្លែងនៅក្នុងរដ្ឋទាំងមូល។ ក្រុមនេះបានប្រាស្រ័យទាក់ទងជាមួយអភិបាលរដ្ឋ Deval Patrick ដើម្បីជំរុញលើកទឹកចិត្តគាត់ឲ្យចេញបទបញ្ជា EJ EO និងជ្រើសរើសមនុស្សមកកាន់មុខតំណែងនាយក EJ ដែលនៅទំនេរ។ ក្រុមនេះចាប់ផ្តើមព្រៀងបទបញ្ជា EJ EO ដើម្បីដាក់ជូនទៅការិយាល័យប្រតិបត្តិនៃកិច្ចការថាមពលនិងបរិស្ថាន (EEA)។
- **2011-2012៖** អង្គការ ACE បានជួយនាយកដ្ឋានការពារបរិស្ថាននៃរដ្ឋម៉ាសាជូសិត (MassDEP) រៀបចំផែនការកិច្ចប្រជុំពិគ្រោះ យោបល់ចំនួន 5 នៅទូទាំងរដ្ឋ។ បទបញ្ជា EJ EO គឺជាតម្រូវការដែលត្រូវបានទាមទារនៅគ្រប់កិច្ចប្រជុំពិគ្រោះយោបល់ទាំងអស់។
- **2013**៖ អង្គការ ACE បានដាក់ជូនសេចក្តីព្រៀងនៃបទបញ្ជា EO ទៅកាន់ការិយាល័យ EEA។ បុគ្គលិករបស់អភិបាលរដ្ឋ Patrick បានសហការជាមួយអង្គការសម្ព័ន្ធ EJ Alliance ដើម្បីតាក់តែងបទបញ្ជា EO។
- **2014**៖ អង្គការសម្ព័ន្ធ MA EJ Alliance បានជួបប្រជុំជាមួយការិយាល័យ EEA ចាប់ពីរដូវរងាររហូតដល់រដូវផ្ការីក ឆ្នាំ2014 ដើម្បីបន្តកិច្ចពិភាក្សាស្តីពី EJ EO។ អង្គការ MA EJ Alliance បានជួបប្រជុំជាមួយនាយកដ្ឋាន DEP ផងដែរ ដើម្បីពិភាក្សាអំពីការបង្កើនការយកចិត្តទុកដាក់ចំពោះក្នុងប្រជាជនចូលរួមក្នុង EJ។ ការិយាល័យអភិវឌ្ឍសេដ្ឋកិច្ចនិងលំនៅដ្ឋានរដ្ឋម៉ាសាជូសិត(HED) ការិយាល័យ EEA និង MassDOT ត្រូវបានអញ្ជើញឲ្យចូលរួមក្នុងកិច្ចពិភាក្សាអំពី EO។ បទបញ្ជា EO ត្រូវបានចុះហត្ថលេខាក្នុងឆ្នាំ2014។
- **2015**៖ ការិយាល័យ EEA បានចេញផ្សាយព័ត៌មានថ្មីចុងក្រោយបំផុត ស្តីពីគោលនយោបាយ EJ របស់រដ្ឋនៅក្នុងខែមករា។ នៅក្នុងការចេញផ្សាយព័ត៌មានថ្មីចុងក្រោយបំផុតនេះ រដ្ឋបានពិនិត្យមើលនិងធ្វើបច្ចុប្បន្នភាពទិន្នន័យប្រជាសាស្ត្រដែលត្រូវបានប្រើប្រាស់ដើម្បីកំណត់សង្កាត់ EJ។ នៅក្នុងខែឧសភា ទីភ្នាក់ងាររដ្ឋនានាមិនអាចបំពេញតាមកាលកំណត់ក្នុងការអនុវត្តយុទ្ធសាស្ត្រ EJ ហើយមុខ តំណែងនាយក EJ គឺបន្តស្ថិតនៅទំនេរ។ មុខតំណែងនាយកនេះស្ថិតនៅទំនេរអស់រយៈពេលជាង 3ឆ្នាំមកហើយ។

- **2018**៖ ក្រុមចម្រុះ EJ ត្រូវបានបង្កើតឡើង៖

បន្ទាប់មក Sofia អញ្ជើញ Staci Rubin ដែលជាអនុប្រធានចលនាយុត្តិធម៌បរិស្ថាននៅ CLF ថ្លែងអំពីលក្ខណៈវិនិច្ឆ័យនៃនិយមន័យរបស់ EJ។ មតិយោបល់ទាំងនេះត្រូវបានសង្ខេបនៅទីនេះ៖

> ក្នុងអំឡុងពេលនៃផ្នែកខាងដើមនៃកិច្ចប្រជុំផ្នែកច្បាប់ចុងក្រោយ ក្រុមចម្រុះ EJ បានពិនិត្យមើលជម្រើសថាតើត្រូវកំណត់និយមន័យប្រជាជនចូលរួមក្នុង EJ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យបែបប្រជាសាស្ត្រឬលក្ខណៈវិនិច្ឆ័យបែបប្រជាសាស្ត្រ ដែលបន្ថែមទៅលើការប៉ះពាល់នឹងអតីតតំបន់ឧស្សាហកម្មឬតំបន់ដែលមានគ្រោះថ្នាក់ ឬទីកន្លែងផ្សេងទៀត។
>
> ក្រុមចម្រុះ EJ បំពេញការងារជាមួយសមាជិកសភាតំណាងថ្នាក់រដ្ឋដែលផ្តួចផ្តើមតាក់តែងច្បាប់។ សមាជិកសភាថ្នាក់រដ្ឋ Miranda សមាជិកសភាថ្នាក់រដ្ឋ DuBois Madaro, Senator DiDomenico, និង Senator Eldridge ទៅលើច្បាប់ស្តីពី“ច្បាប់បង្កើតផែនទីបង្ហាញផ្លូវជំនាន់ថ្មីសម្រាប់គោលនយោបាយអាកាសធាតុរដ្ឋម៉ាសាជូសេត”។ ពួកគេក៏បានសហការជាមួយអ្នកជំនាញផ្នែកទិន្នន័យនិងគូសផែនទីដូចជា បណ្ឌិត Marcos Luna។ ក្រុមចម្រុះ EJ គឺជាក្រុមតស៊ូមតិឈានមុខ ដែលគាំទ្រច្បាប់ស្តីពីអាកាសធាតុ។
>
> ក្តីព្រួយបារម្ភមួយដែលត្រូវបានពិភាក្សា គឺការធ្វើឲ្យមានតុល្យភាពនូវសេចក្តីប្រាថ្នាដើម្បីធានាថាការកំណត់ EJ សម្រាប់សហគមន៍ប្រជាជនចម្រុះពណ៌សម្បុរ ត្រូវបានការពារ និងត្រូវបានទទួលយកយ៉ាងទូលំទូលាយ និងក្តីព្រួយបារម្ភអំពីការមិនដាក់បញ្ចូលបន្ថែមនូវសហគមន៍ដែលមានទ្រព្យធនច្រើនជាង។
>
> ក្រុមចម្រុះបានពិនិត្យមើលការសិក្សាស្រាវជ្រាវជាច្រើន និងបទពិសោធន៍របស់ប្រជាជននានា ហើយការត្រួតពិនិត្យនេះបង្ហាញថាជាតិសាសន៍គឺជាកត្តាចម្បងដែលព្យាករណ៍អំពីការរស់នៅក្បែរមូលដ្ឋានដែលបំពុលធ្ងន់ធ្ងរ ឬដែលប្រកបដោយគ្រោះថ្នាក់។ លក្ខណៈវិនិច្ឆ័យទី4 ដែលបូកបញ្ចូលជាតិសាសន៍ជាមួយនិងប្រាក់ចំណូល មានគោលដៅធានាថាសហគមន៍ប្រជាជនចម្រុះពណ៌សម្បុរ ត្រូវបានការពារ ប៉ុន្តែត្រឹមកម្រិតប្រាក់ចំណូលជាក់លាក់ណាមួយតែប៉ុណ្ណោះ។
>
> បន្ទាប់មកក្រុមចម្រុះ ក៏ចង់ពិចារណាថាតើគេគួរពិនិត្យមើលការប៉ះពាល់ ដែលជាលក្ខណៈវិនិច្ឆ័យបន្ថែមទៅលើកត្តាប្រជាសាស្ត្រដែរឬទេ ក៏ប៉ុន្តែពួកគេមានការលំបាកក្នុងការធ្វើដូច្នោះ ហេតុដូច្នេះក្រុមចម្រុះបានកំណត់កម្រិតកំណត់ (ចំនួនភាគរយ) ដើម្បីចងភ្ជាប់ជាមួយលក្ខណៈវិនិច្ឆ័យផ្អែកប្រជាសាស្ត្រ។
>
> Sofia បានប្រាប់ក្រុមប្រឹក្សា EJ ថាក្រុមប្រឹក្សានេះមានសមត្ថភាពអាចបញ្ចេញឥទ្ធិពលទៅលើកម្រិតកំណត់ជាភាគរយ ដែលជាលក្ខណៈវិនិច្ឆ័យដើម្បីកំណត់ថាអ្នកណាមានលក្ខណៈសម្បត្តិគ្រប់គ្រាន់អាចក្លាយជាក្រុមប្រជាជនចូលរួមក្នុង EJ។ Staci ក៏បានថ្លែងអំពីលក្ខខណ្ឌតម្រូវសម្រាប់សហគមន៍ដាក់ញត្តិដើម្បីស្ម័គ្រចិត្តចូលរួមក្នុងតំបន់ភូមិសាស្ត្រតូចជាងដែលបំពេញលក្ខណៈវិនិច្ឆ័យមួយក្នុងចំណោមលក្ខណៈវិនិច្ឆ័យ EJ។ ក្រុមប្រឹក្សា EJ អាចជួយកំណត់នូវកិច្ចដំណើរការនៃការស្ម័គ្រចិត្តចូលរួម។ សំណួរមួយសម្រាប់ក្រុមប្រឹក្សា EJ យកមកពិចារណា គឺតើអ្នកណាត្រូវផាត់ចេញពីការកំណត់ថាជាប្រជាជនចូលរួមក្នុង EJ។ ជាឧទាហរណ៍ សហគមន៍ Cape Verdean មួយនៅក្នុងក្រុង East Freetown ចង់ទទួលបានការកំណត់និយមន័យថាសហគមន៍ខ្លួនជាប្រជាជនចូលរួមក្នុង EJ (តំបន់ចម្រៀកដីសដែលមានប្រវែងមួយម៉ាយល៍ដែលជួបប្រទះគ្រោះមហន្តរាយបរិស្ថានជាច្រើន)។ ក្រុមចម្រុះយុត្តិធម៌បរិស្ថានមិនអាចស្វែងរកទិន្នន័យនិងកម្រិតកំណត់ ដើម្បីបញ្ចូលក្រុង East Freetown ប៉ុន្តែសង្ឃឹមថាពួកគេអាចដាក់ញត្តិដើម្បីស្ម័គ្រចិត្តចូលរួម។ ក្រុមចម្រុះ EJ សង្ឃឹមថា ក្រុមប្រឹក្សា EJ នឹងគិតអំពីវិធីសាស្ត្រ ដែលយើងអាចធានាឲ្យមានកិច្ចការពារទូលំទូលាយដោយផ្អែកលើកត្តាប្រជាសាស្ត្រសម្រាប់ការកំណត់និយមន័យ ប្រជាជនចូលរួមក្នុង EJ និងគិតម៉ត់ចត់អំពី

ទីកន្លែងមួយចំនួនតូចដែលបំពេញតាមលក្ខណៈវិនិច្ឆ័យជាច្រើនដែលមានសិទ្ធិអាចទទួលបានមូលនិធិគោលដៅ។ ក្រុមចម្រុះក៏សង្ឃឹមថា ក្រុមប្រឹក្សា EJ នឹងប្រើឥទ្ធិពលរបស់ខ្លួនទៅលើកិច្ចដំណើរការផលប៉ះពាល់បន្ថែមដែលកំពុងអនុវត្តជាមួយទីភ្នាក់ងារនានា។

បន្ទាប់មក Sofia អញ្ជើញ Andrea Nyamekye ដែលធ្លាប់បម្រើការងារឲ្យអង្គការ Neighbor to Neighbor ថ្លែងអំពីច្បាប់អាកាសធាតុ និងសារៈសំខាន់របស់ច្បាប់នេះ។ មតិយោបល់របស់ Andrea ត្រូវបានសង្ខេបនៅទីនេះ៖

ដោយសារឥឡូវនេះមានច្បាប់យុត្តិធម៌បរិស្ថាន វាតម្រូវឲ្យមានយុត្តិធម៌តាមបែបនីតិវិធីនិងសារធាតុ។ វាតម្រូវឲ្យទទួលបានសេវាភាសានិងយុត្តិធម៌សារធាតុ ដូចជាការទទួលស្គាល់បន្ទុកដែលមិនស្មើគ្នា និងកែតម្រូវបន្ទុកទាំងនេះ។ មុនពេលមានច្បាប់យុត្តិធម៌បរិស្ថាន ទីភ្នាក់ងារនានាពុំចាំបាច់ត្រូវគិតគូរពិចារណាបែងចែកផលប្រយោជន៍និងបន្ទុកនានានៅពេលអនុវត្តកិច្ចដំណើការផ្តល់ការអនុញ្ញាតដល់មូលដ្ឋានថាមពលនានា ឬគិតគូរពិចារណាទៅដល់ប្រជាជនចូលរួមក្នុង EJ នៅពេលអនុវត្តកិច្ចដំណើរការផ្តល់សេវាឆ្លងកាត់។

Andrea បានអញ្ជើញ Maria Belen បញ្ចប់បទបង្ហាញរបស់ក្រុមចម្រុះយុត្តិធម៌បរិស្ថាន។ Maria Belen និយាយសង្កត់ធ្ងន់បន្ថែមទៅលើបំណងប្រាថ្នារបស់ក្រុមចម្រុះ EJ ក្នុងការសហការ ជាមួយក្រុមប្រឹក្សា EJ ដើម្បីពង្រឹងលើកកម្ពស់ EJ នៅពាសពេញទូទាំងរដ្ឋម៉ាសាជូសិត។ Maria Belen បានផ្ញើរសារអ៊ីម៉ែលទៅកាន់សមាជិកក្រុមប្រឹក្សាយុត្តិធម៌បរិស្ថានដើម្បីជួបប្រជុំជាក្រុមដែលមានសមាជិកបីឬបួននាក់ ដើម្បីគោរពអនុវត្តតាមច្បាប់ស្តីពីកិច្ចប្រជុំចំហ (OML)។

**ការវិភាគនិយមន័យ "ប្រជាជនចូលរួមក្នុង EJ"៖**

ប្រវត្តិសង្ខេបនៃគោលនយោបាយ EJ ត្រូវបានបង្ហាញដោយបណ្ឌិត Marcos Luna ដែលជាសាស្ត្រាចារ្យជំនាញភូមិវិទ្យានិងចិរភាព និងជាអ្នកសម្របសម្រួលកម្មវិធីសិក្សាក្រោយឧត្តមផ្នែកវិទ្យាសាស្ត្រព័ត៌មានភូមិវិទ្យានៃសាកលវិទ្យាល័យ Salem State។

Rishi បើកវេទិកាសម្រាប់ក្រុមប្រឹក្សា EJ ពិភាក្សាអំពីផលិតផលការងាររបស់ខ្លួន។ កិច្ចពិភាក្សាទូទៅត្រូវបានសង្ខេបនៅទីនេះ៖

Rishi - តើផលិតផលការងាររបស់ក្រុមប្រឹក្សានេះគួរមានទម្រង់បែបណា? តើអ្វីដែលយើងបង្ហាញនៅចុងបញ្ចប់នៃការវិភាគ គួរតែជារបាយការណ៍ជាលាយលក្ខអក្សរដែរឬទេ? ឬជារបាយការណ៍ផ្ទាល់មាត់? ឬជារបាយការណ៍ដែលផ្សំបញ្ចូលទម្រង់ទាំងពីរ? តើយើងត្រូវសម្រេចដោយរបៀបណា? តើយើងគួរបំបែកជាក្រុមតូចៗដែរឬទេ?

Pat Spence - ឯកសារជាលាយលក្ខអក្សរមានសារៈសំខាន់ ប៉ុន្តែនៅពេលណាដែលយើងអាចធ្វើបាន យើងគួរអញ្ជើញ អ្នកណាម្នាក់មកចូលរួមដើម្បីស្តាប់អ្វីដែលយើងកំពុងនិយាយ ការអនុវត្តបែបនេះនឹងធ្វើឲ្យអនុសាសន៍នានាមានលក្ខណៈបុគ្គលផ្ទាល់យ៉ាងខ្លាំង។

Rishi - តួនាទីរបស់ក្រុមប្រឹក្សា EJC គឺផ្តល់អនុសាសន៍ដល់លេខាធិការនិងបុគ្គលិកជាន់ខ្ពស់។

Kahlila - បន្ថែមទៅលើលេខាធិការ តើមានកិច្ចដំណើការណាមួយសម្រាប់បង្ហាញលទ្ធផលការងារទៅដល់សាធារណជនដែរឬទេ?

Rishi - បរិបទសម្រាប់កិច្ចការងាររបស់យើង គឺថារបាយការណ៍ណាមួយដែលផ្តល់អនុសាសន៍ជូនដល់លេខាធិការ និងបុគ្គលិករបស់គាត់ គឺជាឯកសារសាធារណៈ ហេតុដូច្នេះមនុស្សគ្រប់រូបអាចទទួលបានឯកសារនេះ។

Rishi - គំនិតបន្ថែមផ្សេងទៀតអាចត្រូវផ្ញើជាសារអ៊ីម៉េលដោយផ្ទាល់ទៅកាន់ Val (Vallery Cardoso) សូមចម្លងជូនទៅកាន់សមាជិកដទៃទៀតរបស់ក្រុមប្រឹក្សានៅលើសារអ៊ីម៉េលនោះ។ សេចក្តីសម្រេចរវាងក្រុមប្រឹក្សា អាចនឹងកើតឡើងនៅក្នុងកិច្ចប្រជុំផ្លូវការនេះតែប៉ុណ្ណោះ ដោយអនុលោមតាមច្បាប់ស្តីពីកិច្ចប្រជុំចំហ។

Rishi - ដោយផ្អែកលើអ្វីដែលយើងបានស្តាប់ឮ តើកិច្ចការ/ការសិក្សាស្រាវជ្រាវអ្វីបន្ថែមផ្សេងទៀតដែលចាំបាច់ត្រូវអនុវត្តដើម្បីធ្វើការសម្រេចចិត្តអំពីចំនួនភាគរយនៃចំនួនប្រជាជនចូលរួមក្នុង EJ?

Cheryll Holley - សេចក្តីថែងអំពី “ស្ម័គ្រចិត្តចូលរួម” សម្រាប់សហគមន៍ EJ ដូចមានចែងនៅក្នុងលក្ខន្តិកៈ។ តើសេចក្តីចែងនេះមានន័យដូចម្តេច? ជួនកាលប្រជាជនដែលមិនមែនជាជនស្បែកស អាចមានប្រាក់ចំណូលទាប ប៉ុន្តែរស់នៅក្នុងសង្កាត់ល្អប្រសើរ។ ហេតុដូច្នេះ តើចំណុចនេះមានន័យបែបណាចំពោះសហគមន៍នានាជាពិសេសសហគមន៍នៅផ្នែកកណ្តាល និងភាគខាងលិចនៃរដ្ឋ?

Rishi - វាជាការពិតដែលថា សេចក្តីចែងអំពីការស្ម័គ្រចិត្តចូលរួម អាចជួយបញ្ជាក់នូវតថភាពសម្រាប់តំបន់មិនមែនភាគខាងកើតនៃរដ្ឋ។

Marcos - សហគមន៍មួយអាចដាក់ញត្តិស្នើសុំលេខាធិការដាក់បញ្ចូលសហគមន៍ខ្លួនទៅក្នុងនិយមន័យប្រជាជនចូលរួមក្នុង EJ។ ព័ត៌មានពិស្តារមិនទាន់ត្រូវបានកំណត់នៅឡើយ។

Cheryll - អញ្ចឹងតើក្រុមកុលសម្ព័ន្ធមួយ អាចធ្វើបែបនេះបានដែរឬទេ?

Marcos - សហគមន៍ដែលត្រូវបានកំណត់អត្តសញ្ញាណ ត្រូវបានកំណត់និយមន័យដោយផ្អែកលើលក្ខណៈវិនិច្ឆ័យភូមិសាស្ត្រ។ ការស្ម័គ្រចិត្តចូលរួម ហាក់ដូចជាគោរពតាមនិយមន័យបែបភូមិសាស្ត្រ។

Melissa - ត្រឡប់ទៅកាន់ពេលវេលាដែលយើងបានពិភាក្សាអំពី Herring Pond និងប្រជាជនកុលសម្ព័ន្ធដទៃផ្សេងទៀត ដែលរស់នៅក្នុងសហគមន៍រមនីយដ្ឋានដូចជា Cape Cod។ យើងអាចបង្កើតស្រទាប់នៃតំបន់បម្រុងនិងតំបន់កំណើតជាប្រពៃណីនៅលើផែនទីនេះ។ មនុស្សជាច្រើនមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ និងគួរត្រូវកំណត់អត្តសញ្ញាណដាក់បញ្ចូល។ តើយើងកំណត់អត្តសញ្ញាណសហគមន៍ទាំងនេះដោយរបៀបណា? មិនត្រឹមតែសហគមន៍កុលសម្ព័ន្ធតែប៉ុណ្ណោះទេ។

Cheryll Holly - សហគមន៍ទាំងអស់មិនមែនសុទ្ធតែអាចកំណត់អត្តសញ្ញាណដោយលក្ខណៈវិនិច្ឆ័យបែបភូមិសាស្ត្រនោះឡើយ។

Rishi - នេះគឺជាបញ្ហាស្មុល ជាពិសេសពាក់ព័ន្ធនឹងក្រុមកុលសម្ព័ន្ធ។ ទោះបីជាប្រជាជនដើមត្រូវកំណត់អត្តសញ្ញាណនៅក្នុងគោលនយោបាយ EJ ថាជាក្រុមជនជាតិភាគតិចក៏ដោយ ការកំណត់អត្តសញ្ញាណនោះ ពុំអាចប្រែក្លាយទៅជារបៀបដែលយើងកត់ត្រាទិន្នន័យនោះនៅលើផែនទី EJ នោះឡើយ។ ដូច្នេះ តើយើងអាចដោះស្រាយបញ្ហានេះដោយរបៀបណា? តើគេត្រូវការព័ត៌មានបន្ថែមអ្វីខ្លះ?

Melissa - នេះគឺជាសំណួរចម្បងមួយសម្រាប់សហគមន៍កុលសម្ព័ន្ធ។ វាគឺជាបញ្ហាសម្រាប់ប្រជាជាតិកុលសម្ព័ន្ធនីមួយៗ ហើយបញ្ហានេះ មានលក្ខណៈផ្ទាល់យ៉ាងខ្លាំងចំពោះក្រុមកុលសម្ព័ន្ធនោះ។

Cheryll - ក្រុមកុលសម្ព័ន្ធនានា កំពុងពិភាក្សាអំពីរឿងនេះរួចទៅហើយ។

Lydia Lowe - យល់ស្របជាមួយអ្នកដទៃផ្សេងទៀតអំពីការលាយបញ្ចូលគ្នារវាង ទម្រង់ជាលាយលក្ខអក្សរ និងទម្រង់ផ្ទាល់មាត់សម្រាប់ផលិតផលការងារ។ ចំពោះការងារមួយចំនួនដែលចាំបាច់ត្រូវអនុវត្ត ដោយកោតសរសើរចំពោះភាពស្មុគស្មាញនៃកិច្ចការងារនេះ។ មានអារម្មណ៍ថាចាំបាច់ត្រូវសិក្សារៀនសូត្របន្ថែមទៀត ពីព្រោះខ្ញុំយល់ដឹងតែអំពីសហគមន៍របស់ខ្ញុំតែប៉ុណ្ណោះ។ តើមានផែនទីស្តីពីប្រភេទផ្សេងៗគ្នានៃការបំពុលបរិស្ថាន និងប្រវត្តិនិងស្ថានភាពបច្ចុប្បន្នរបស់សហគមន៍កុលសម្ព័ន្ធដែរឬទេ? មានរឿងរ៉ាវច្រើនដែលត្រូវសិក្សារៀនសូត្រ។

Rishi - យើងម្នាក់ៗ មានជំនាញឯកទេសផ្សេងៗគ្នា។ របៀបដែលយើងប្រើប្រាស់ជំនាញទាំងនោះ ហើយធ្វើការសម្រេចចិត្តរួមគ្នា គឺជាគន្លឹះដ៏សំខាន់សម្រាប់ក្រុមនេះ។

Caroline Hon - តើមានការប្រៀបធៀបជាមួយរដ្ឋដទៃទៀតអំពីកម្រិតកំណត់ដែរឬទេ? ប្រសិនបើមាន តើព័ត៌មាននោះអាចត្រូវចែករំលែកបានដែរឬទេ?

Rishi – ពិតជាបាន យើងរក្សាការប្រាស្រ័យទាក់ទងជាមួយរដ្ឋដទៃផ្សេងទៀត និងវាយតម្លៃអំពីអ្វីដែលត្រូវបានអនុវត្តនៅទីនោះ ប៉ុន្តែយើងត្រូវចងចាំថា រដ្ឋនីមួយៗមានលក្ខណៈពិសេសដាច់ដោយឡែកពីគ្នា។ រដ្ឋញូជឺស៊ីនិងកាលីហ្វ័រញ៉ា គឺជាឧទាហរណ៍មួយសម្រាប់វិស័យនេះ។

Pat Spence - មានព័ត៌មានច្រើនណាស់ ខ្ញុំពុំមានអារម្មណ៍ថាខ្ញុំត្រៀមខ្លួនរួចរាល់ដើម្បីចូលទៅក្នុងក្រុមតូច ប៉ុន្តែយើងកំពុងរៀនសូត្រថាតើយើងជានរណា ហើយខ្ញុំមិនចង់ខកខានក្នុងការស្វែងយល់ពីទស្សនៈរបស់គ្នាយើងទៅវិញទៅមកនោះឡើយ។

Peter - ការស្វែងយល់និងការសិក្សាស្រាវជ្រាវពីអ្វីដែលមានអត្ថិភាព។ តើមានសំណើ ឬទិន្នន័យណាដែលយើងអាចយកមកធ្វើការពិចារណាឆ្លុះបញ្ចាំងបានដែរឬទេ? តើយើងដឹងដោយរបៀបណា ថាពេលណាយើងបានធ្វើការសម្រេចចិត្តរួចរាល់? ចង់ឃើញវាត្រូវគេដាក់ចេញមក។ និងបណ្ណុំព័ត៌មាននៅមួយកន្លែង ដើម្បីអនុញ្ញាតឲ្យយើងអាចពិនិត្យមើលព័ត៌មានទាំងអស់។ តើយើងអាចសម្រេចបាននូវការយល់ដឹងដូចគ្នាដោយរបៀបណា?

Kahlila - ប្រសិនបើយើងចូលទៅក្នុងក្រុមការងារ តើមានជំនួយគាំទ្រអ្វីខ្លះ? តើយើងរៀបចំកាលវិភាគពេលវេលាដោយខ្លួនឯងផ្ទាល់មែនដែរឬទេ? តើវានឹងត្រូវគ្រប់គ្រងដោយរបៀបណា? ប្រសិនបើមានអ្នកជំនាញក្នុងវិស័យជាក់លាក់ណាមួយ តើយើងអាចប្រឹក្សាយោបល់ជាមួយពួកគេបានដែរឬទេ?

Rishi - ប្រសិនបើអ្នកណាម្នាក់មានគំនិតណាផ្សេងទៀត សូមផ្ញើគំនិតនោះទៅកាន់ Vallery នៅត្រឹមថ្ងៃទី21 ខែកញ្ញា ដែលនឹងទាន់ពេលសម្រាប់កិច្ចប្រជុំបន្ទាប់។

Rishi- ខ្ញុំកំពុងប្រមូលផ្តុំធនធានជាលាយលក្ខអក្សរនិងរូបភាពវីដេអូ ដែលក្រុមប្រឹក្សាអាចនឹងប្រើប្រាស់ធនធានទាំងនេះ។ ដើម្បីបង្កលទ្ធភាពឲ្យយើងអាចបោះជំហានទៅមុខស្មើគ្នា។

## បទបង្ហាញស្តីពីផែនការថាមពលស្អាត និងអាកាសធាតុ៖

Hanh Chu ដែលជាអ្នកគ្រប់គ្រងកម្មវិធីស្តីពីច្បាប់ GWSA ផ្តល់ព័ត៌មានស្តីពីផែនការថាមពលស្អាតនិងអាកាសធាតុឆ្នាំ2050។ សំណួរដូចខាងក្រោមត្រូវបានសាកសួរ ហើយចម្លើយត្រូវបានផ្តល់ជូន៖

Marcos - តើផែនការកាត់បន្ថយឧស្ម័នកាបូនិកមានខ្នាតរង្វាស់ពាក់ព័ន្ធនឹងសមធម៌នៃការអនុវត្តដែរឬទេ? តើមានផែនការសម្រាប់វាស់វែងវាដែរឬទេ?

Hanh – យើងកំពុងធ្វើការងារលើផ្ទាំងទិន្នន័យលើអនឡាញ ដែលយើងនឹងអាចតាមដានការវិវត្តរីកចម្រើននៃគោលដៅនិងការប្តេជ្ញាចិត្តនានារបស់ផែនការ។ កំណែដើមដំបូងបច្ចុប្បន្ននៃផ្ទាំងទិន្នន័យ មិនមានខ្នាតរង្វាស់សមធម៌នោះឡើយ ប៉ុន្តែនោះគឺជាអ្វីដែលយើងចង់សម្រេចបានសម្រាប់កំណែប្រែបន្ទាប់ ដែលនឹងត្រូវដាក់ឲ្យប្រើប្រាស់នៅឆ្នាំក្រោយ។ ក្រុមរបស់ Hanh បានចូលរួមជាមួយគណៈកម្មការប្រឹក្សាយោបល់អំពីការអនុវត្ត (IAC) នៃច្បាប់ GWSA ពាក់ព័ន្ធនឹងខ្នាតរង្វាស់ដែលពួកគេឃើញហើយពួកគេក៏បានលើកឡើងនូវសារៈសំខាន់នៃការវាស់វែងការអនុវត្តដែលផ្តោតលើសមធម៌ ដែលជាមូលហេតុដែលធ្វើឲ្យពួកគេផ្តល់អនុសាសន៍មួយចំនួននៃខ្នាតរង្វាស់សមធម៌។ ក្រុមការងារយុត្តិធម៌អាកាសធាតុ (Climate Justice Working Group) នៃគណៈកម្មការប្រឹក្សាយោបល់អំពីការអនុវត្ត (IAC) នៅឆ្នាំ2020 ក៏បានផ្តល់ខ្នាតរង្វាស់ដែលត្រូវបានស្នើឡើងផងដែរ។ នឹងធ្វើការពិនិត្យនៅឆ្នាំក្រោយដើម្បីកំណត់ថាតើនៅក្នុងចំណោមខ្នាតរង្វាស់ទាំងនោះ តើខ្នាតរង្វាស់ណាមួយដែលយើងវិភាគមានទិន្ន័យដែលអាចជឿទុកចិត្តបាន និងពិនិត្យតាមដានប្រចាំឆ្នាំឬជាទៀងទាត់។

Marcos - ប្រសិនបើអាចធ្វើទៅបាន ចូរសួរថាតើទិន្ន័យដែលត្រូវប្រមូលបានតែងតែត្រូវភ្ជាប់ជាមួយលក្ខណៈភូមិសាស្ត្រតាមរបៀបណាមួយទើបអាចរាយការណ៍បានមែនដែរឬទេ។ ទន្ទឹមនឹងនេះប្រសិនបើនៅកម្រិតគ្រួសារ ព័ត៌មានមូលដ្ឋានដែលត្រូវបានធ្វើឲ្យមានលក្ខណៈអនាមិកស្តីពីអ្នកទទួលបានសេវាទាំងនោះ។

ពុំមានសំណួរណាផ្សេងទៀត ត្រូវបានសួរនៅក្រោយពេលនៃបទបង្ហាញរបស់ Hanh នោះឡើយ។

## សំណួរ/មតិយោបល់ពីសាធារណជន៖

Rishi បានសាកសួរ Vallery តើមានមតិយោបល់ពីសាធារណជននៅក្នុងប្រអប់សំណួរចម្លើយរបស់ប្រព័ន្ធZoom ដែរឬទេ។ ពុំមានសំណួរនៅក្នុងប្រអប់សំណួរចម្លើយនោះឡើយ ប៉ុន្តែសមាជិកនៃធារណជនបានលើកដៃតាមអនឡាញ ដើម្បីសុំសិទ្ធិនិយាយ។ សំណួរនោះ មកពី Melanie Gárate។ Melanie បានសួរថាតើក្រុមប្រឹក្សាយល់ឃើញថារដ្ឋបាលថ្មីនឹងបង្កផលប៉ះពាល់បែបណាទៅលើកិច្ចការងារដែលក្រុមប្រឹក្សានេះកំពុងអនុវត្ត។ Rishi បានឆ្លើយតបថា ក្រុមប្រឹក្សា EJ នឹងបន្តដំណើរការជាស្ថាប័នមួយ ហើយយើងទាំងអស់គ្នានឹងសិក្សាស្វែងយល់អំពីអាទិភាពនានារបស់រដ្ឋបាលថ្មីនោះ។ Melanie ក៏បានស្នើសុំក្រុមប្រឹក្សា EJ ផ្តល់ព័ត៌មានអំពីការផ្លាស់ប្តូរណាមួយជូនដល់សាធារណជន។

Patricia Spence បានសាកសួរអំពីវិធីសាស្ត្រដែលយើងអាចរួមបញ្ចូលប្រជាជនដែលមានវ័យចាស់ ទៅក្នុងកិច្ចការនេះ។ នៅពេលយើងពិនិត្យមើល EJ វាកើតឡើងចំពោះឪពុកម្តាយនិងជីដូនជីតារបស់យើង ហេតុដូច្នេះតើ

យើងអាចរួមបញ្ចូលពួកគេដោយវិធីណា?
ជាពិសេសនៅពេលដែលពួកគេស្ថិតនៅទីតាំងបច្ចេកវិទ្យាមួយផ្សេងខុសប្លែកពីយើង។ Rishi បានឆ្លើយតបថា កិច្ចប្រជុំទូរនិម្មិត ពុំមែនជាជម្រើសល្អនោះទេ ប៉ុន្តែ វាជួយធ្វើឲ្យក្រុមជាក់លាក់នានាអាចចូលរួមបានកាន់តែច្រើន។ កម្មវិធី Zoom ពុំមានជម្រើសនៃការហៅទូរសព្ទចូលនោះឡើយ។ មនុស្សចាស់គឺជាក្រុមមនុស្សដ៏សំខាន់ ហើយពួកគេចូលរួមក្នុងកិច្ចសន្ទនាជាច្រើន ក្នុងនាមជាសមាជិកនៃប្រជាជនដែលងាយរងគ្រោះពីអាកាសធាតុ និងភាពងាយរងគ្រោះផ្នែកសុខាភិបាលសាធារណៈ។

## ជំហានបន្ទាប់ និងការលើកវារកាលៈ

Rishi បានប្រកាសថា កិច្ចប្រជុំបន្ទាប់របស់ក្រុមប្រឹក្សាយុត្តិធម៌បរិស្ថាន នឹងត្រូវធ្វើឡើងនៅថ្ងៃអង្គារ ទី27 ខែកញ្ញា នៅម៉ោង 12 ថ្ងៃត្រង់។ កិច្ចប្រជុំនេះនឹងត្រូវរៀបចំបែបតាមអ៊ីនធឺណិតនៅលើប្រព័ន្ធ Zoom។ របៀបវារៈសម្រាប់កិច្ចប្រជុំនោះ មានដូចខាងក្រោមៈ ទម្រង់នៃផលិតផលការងារ និងវិធីសាស្ត្រដើម្បីសម្រេចបានផលិតផលបែបនោះ និងការណែនាំបង្ហាញក្រុមការងារEJ របស់ការិយាល័យ EEA។

Rishi បានថ្លែងថា មតិយោបល់កែលម្អណាមួយចំពោះរបៀបវារៈទាំងនេះ អាចនឹងត្រូវផ្ញើបញ្ជូនទៅកាន់ Vallery។
Namrita បញ្ចេញមតិយោបល់ថា ព័ត៌មានដែលត្រូវបានផ្តល់ជូនក្រុមប្រឹក្សា EJ និយាយអំពីចំណុចដែលនិយមន័យ ធ្វើឲ្យយើងបរាជ័យធំបំផុត និងថាការរួមបញ្ចូលក្រុមមនុស្សបានច្រើន គឺល្អប្រសើរជាងការរួមបញ្ចូលក្រុមមនុស្សតិចតួច។ Namrita បានសាកសួរអំពីចំណុចដែលនិយមន័យនោះមិនដំណើរការល្អ និងថាតើក្រុមប្រឹក្សា EJ អាចទទួលបានទិន្នន័យមួយចំនួនស្តីពីចំណុចនោះដែរឬទេ។ Rishi បានឆ្លើយតបថា មានព័ត៌មាននៅខាងក្រៅ ហើយកិច្ចការមួយក្នុងចំណោមកិច្ចការនានាដែលក្រុមការងារនេះនឹងអនុវត្ត គឺពិនិត្យព័ត៌មាននោះនិងស្វែងរកការពិតថាតើវាអាចប៉ះពាល់ដល់និយមន័យតាមរបៀបណា។

Rishi បានផ្តល់ការអនុញ្ញាតឲ្យលើកជាសំណើផ្អាកការប្រជុំ។ Namrita បានស្នើសុំផ្អាកការប្រជុំ ហើយ Cheryll គាំទ្រសំណើនោះ។ Rishi បានហៅឈ្មោះអ្នកចូលរួមដើម្បីធ្វើការបោះឆ្នោត។ សមាជិកទាំងអស់បានបោះឆ្នោតយល់ព្រមផ្អាកការប្រជុំ។ កិច្ចប្រជុំត្រូវបានផ្អាកនៅម៉ោង 12:32 នាទី ថ្ងៃទី15 ខែកញ្ញា ឆ្នាំ2022។